ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ១៦០/១៤ ក.អ.ជ.ប្រក

ថ្ងៃចន្ទ ១២ កើត ខែជេស្ឋ ឆ្នាំមមី ព.ស. ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា គ.ស. ២០១៤

# ប្រកាស

## ស្ដីពី

## ការបង្កើត និងតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ សម្រាប់គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មរបស់គម្រោងកែលម្អផ្លូវជនបទជំហានទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្ដីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងកំណត់ហេតុកិច្ចប្រជុំចរចាឥណទានរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ១.-** បង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មសម្រាប់គម្រោងកែលម្អផ្លូវជនបទជំហានទី ២ និងតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការសម្រាប់បំពេញការងារ គណៈកម្មការ មានដូចខាងក្រោម÷



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

ក. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មកម្រិតធំ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **សួស គង់** | ជាប្រធាន |
| ២. | ឯកឧត្តម | **ចាន់ ដារ៉ុង** | ជាសមាជិក |
| ៣. | លោក | **សុខ សុផល** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២រូប | | ជាសមាជិក |

ខ. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មទូទៅ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | **ចាន់ ដារ៉ុង** | ជាប្រធាន |
| ២. | លោក | **សុខ សុផល** | ជាសមាជិក |
| ៣. | លោក | **សាន វិសាល** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២រូប | | ជាសមាជិក |

គ. គណៈកម្មការត្រួតពិនិត្យកិច្ចការលទ្ធកម្មកម្រិតតូច

| | | | |
|---|---|---|---|
| ១. | លោក | **នួច សំណាង** | ជាប្រធាន |
| ២. | លោក | **ញៀម សុគន្ធា** | ជាសមាជិក |
| ៣. | កញ្ញា | **ដាំ ដារីណុច** | ជាសមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២រូប | | ជាសមាជិក |

**ប្រការ ២.-** តែងតាំងគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោក | **ស្រ៊ន់ ពិឆ្ង** | ប្រធាន |
| ២. | លោក | **សារី សុខុម** | សមាជិក |
| ៣. | លោក | **ឈា ទ៉េងហ៊ុយ** | សមាជិក |

**ប្រការ ៣.-** មន្ត្រីរាជការដូចមានក្នុងប្រការ ១ និងប្រការ ២ មានភារកិច្ចទទួលខុសត្រូវ ដឹកនាំ ត្រួតពិនិត្យកិច្ចការលទ្ធកម្មគម្រោងកែលម្អផ្លូវជនបទដំណាក់កាលទី ២ ក្រោមហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

**ប្រការ ៤.-** សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥-** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ ១ និងប្រការ ២ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**កន្លែងទទួល**

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*
*-មន្ទីរពាក់ព័ន្ធ*
*"ដើម្បីជូនជ្រាប"*
*-ដូចប្រការ៣*
*"ដើម្បីអនុវត្ត"*
*-ឯកសារ - កាលប្បវត្តិ*

**ជា សុផារ៉ា**